ឯកឧត្តមទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** បានដឹកនាំមន្ត្រីជាន់ខ្ពស់ចូលរួមគោរពវិញ្ញាណក្ខន្ធ ឯកឧត្តម ឈឹម ជួន



នៅថ្ងៃព្រឹកថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៦ ឯកឧត្តមទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** បានដឹកនាំមន្ត្រីជាន់ខ្ពស់នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម ចូលរួមគោរពវិញ្ញាណក្ខន្ធ ឯកឧត្តម ឈឹម ជួន អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជា សមាជិកគណៈកម្មាធិការ កណ្តាលគណបក្សប្រជាជន ដែលបានទទួលមរណភាព កាលពីថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៦ នាវេលាម៉ោង០២:០០នាទីយប់ ក្នុងជន្មាយុ ៧៦ឆ្នាំ ដោយរោគាពាធ។

ក្នុងនាមថ្នាក់ដឹកនាំ និងមន្ត្រីរាជការទាំងអស់នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម រួមទាំងក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ខេត្តកំពត ឯកឧត្តមទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** បានសម្តែងនូវសមានទុក្ខ សោកស្តាយអាឡោះអាល័យ ចំពោះការបាត់បង់នូវឥស្សរជនជាន់ខ្ពស់ មួយរូបរបស់រាជរដ្ឋាភិបាល ដែលបានលះបង់នូវកម្លាំងកាយចិត្ត ធនធាន និងបញ្ញាញាណ ចូលរួមយ៉ាងសកម្ម ក្នុងបុព្វហេតុ បម្រើជាតិមាតុភូមិ។



ក្នុងឱកាសនៃការចូលរួមមរណទុក្ខនេះដែរ ឯកឧត្តមទេសរដ្ឋមន្ត្រី និងមន្ត្រីជាន់ខ្ពស់នៃក្រសួងឧស្សាហកម្ម និងសិប្បកម្មបានចូលរួមរំលែក ទុក្ខយ៉ាងក្រៀមក្រំ ដោយភាពសោកស្តាយ និងអាឡោះអាល័យជាទីបំផុត ជាមួយលោកជំទាវនិងក្រុមគ្រួសារសពឯកឧត្តម ឈឹម ជួន និងបានឧទ្ទិសបួងសួងដល់ដួងវិញ្ញាណក្ខន្ធរបស់លោក បានឆាប់ចាប់បដិសន្ធិសោយសុខក្នុងឋានសុគតិភពៗ។



